ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៦៤ . សសរ

សេចក្តីសម្រេច
ស្តីពី
ការបង្កើតគណៈកម្មាធិការសម្របសម្រួល អនុវត្តន៍ កាតព្វកិច្ចក្រោមក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក និងរៀបចំឯកសារសម្រាប់ត្រួតពិនិត្យគោលនយោបាយពាណិជ្ជកម្មកម្ពុជា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សម្រេច

ប្រការ ១.-

ត្រូវបានបង្កើត "គណៈកម្មាធិការសម្របសម្រួលអនុវត្តន៍ កាតព្វកិច្ចក្រោមក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក និងរៀបចំឯកសារសម្រាប់ត្រួតពិនិត្យគោលនយោបាយពាណិជ្ជកម្មកម្ពុជា"

www.pheakdeylaw.com

ហៅកាត់ថា គ.អ.ក.ព ដើម្បីសម្របសម្រួលជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ សំដៅអនុវត្តន៍កាតព្វកិច្ចរបស់កម្ពុជាក្រោមក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក និងរៀបចំឯកសារនានាសម្រាប់កិច្ចប្រជុំត្រួតពិនិត្យ គោលនយោបាយពាណិជ្ជកម្មកម្ពុជា។

គ.អ.ក.ព មានលេខាធិការដ្ឋាននៅ ក្រសួងពាណិជ្ជកម្ម។ ការរៀបចំ និងប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន គ.អ.ក.ព ត្រូវកំណត់ដោយប្រធាន គ.អ.ក.ព ។

ប្រការ ២.-

គ.អ.ក.ព មានសមាសភាពដូចខាងក្រោម៖

១. រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម	ប្រធាន
២. រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម	អនុប្រធាន
៣. រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	អនុប្រធាន
៤. រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម និងសិប្បកម្ម	សមាជិក
៥. រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ	សមាជិក
៦. រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ	សមាជិក
៧. រដ្ឋលេខាធិការក្រសួងមហាផ្ទៃ	សមាជិក
៨. រដ្ឋលេខាធិការក្រសួងរ៉ែ និងថាមពល	សមាជិក
៩. រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	សមាជិក
១០. រដ្ឋលេខាធិការក្រសួងផែនការ	សមាជិក
១១. រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា	សមាជិក
១២. រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា	សមាជិក
១៣. រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់	សមាជិក
១៤. រដ្ឋលេខាធិការក្រសួងបរិស្ថាន	សមាជិក
១៥. រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម	សមាជិក
១៦. រដ្ឋលេខាធិការក្រសួងព័ត៌មាន	សមាជិក
១៧. រដ្ឋលេខាធិការក្រសួងយុត្តិធម៌	សមាជិក
១៨. រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍	សមាជិក
១៩. រដ្ឋលេខាធិការក្រសួងសុខាភិបាល	សមាជិក
២០. រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន	សមាជិក
២១. រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ	សមាជិក
២២. រដ្ឋលេខាធិការក្រសួងទេសចរណ៍	សមាជិក
២៣. រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ	សមាជិក
២៤. អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម	សមាជិក
២៥. អនុរដ្ឋលេខាធិការ រដ្ឋលេខាធិការដ្ឋាន អាកាសចរណ៍ស៊ីវិល	សមាជិក

www.pheakdeylaw.com

២៦. អគ្គលេខាធិការរងគណៈកម្មការវិនិយោគនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

២៧. ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា សមាជិក

ប្រការ ៣.-

គ.អ.ក.ព មានភារកិច្ចដូចខាងក្រោម៖

- តាមដាន និងសម្របសម្រួលការអនុវត្តកាតព្វកិច្ច និងការសន្យាដែលបានធ្វើឡើងក្រោមក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោកដើម្បីរាយការណ៍ជូនរាជរដ្ឋាភិបាល អំពីវឌ្ឍនភាពការងារ និងទិសដៅដែលត្រូវធ្វើបន្ត
- រៀបចំលិខិតបទដ្ឋានគតិយុត្តិថ្មី ឬ លើកទិសដៅសម្រាប់ធ្វើវិសោធនកម្មលិខិតបទដ្ឋានច្បាប់ជាធរមាន និងកែលម្អគោលនយោបាយពាណិជ្ជកម្ម ឲ្យមានអនុលោមភាព និងសង្គតិភាពជាមួយការសន្យាក្រោមក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក
- រៀបចំឯកសារ និងផ្តល់អនុសាសន៍ជូនរាជរដ្ឋាភិបាល សម្រាប់ចរចាជាមួយបណ្តាប្រទេសក្នុងបរិបទពាណិជ្ជកម្មតំបន់ និងពិភពលោក
- ចងក្រងឯកសារគោលនយោបាយទាក់ទងនិងពាណិជ្ជកម្ម សម្រាប់កិច្ចប្រជុំត្រួតពិនិត្យគោលនយោបាយពាណិជ្ជកម្ម នៅក្នុងក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក
- គៀងគរថវិកាពីដៃគូអភិវឌ្ឍន៍នានាសម្រាប់ជួយដល់ ក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្នុងការអនុវត្តកាតព្វកិច្ច និងការសន្យាក្រោមក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក
- ចូលរួម និងសម្របសម្រួលដល់ការរៀបចំកិច្ចប្រជុំនានា ពាក់ព័ន្ធនិងការត្រួតពិនិត្យ គោលនយោបាយពាណិជ្ជកម្មកម្ពុជា ទាំងក្នុងប្រទេស និងក្រៅប្រទេស
- អនុវត្តន៍ភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន

ប្រការ ៤.-

អនុប្រធាន និងសមាជិក គ.អ.ក.ព ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន ឬមានភារកិច្ចផ្សេង អនុប្រធានត្រូវដឹកនាំប្រជុំជំនួស តាមការប្រគល់ភារកិច្ចពីប្រធាន។ ប្រធាន គ.អ.ក.ព អាចអញ្ជើញមន្ត្រីតំណាងក្រសួង-ស្ថាប័នផ្សេងទៀតឲ្យចូលរួមប្រជុំតាមការចាំបាច់។

ប្រការ ៥.-

ការចំណាយសម្រាប់ដំណើរការ គ.អ.ក.ព ត្រូវយកពីថវិកាជាតិ ក្នុងគម្រោងថវិការបស់ក្រសួងពាណិជ្ជកម្ម ឬថវិកាទទួលបានពីប្រភពស្របច្បាប់ផ្សេងទៀត។

ប្រការ ៦.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

www.pheakdeylaw.com

ប្រការ ៧.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវអនុវត្តន៍សេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ២០១៦

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ប៉ាន សូរស័ក្តិ

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៧ (ដើម្បីអនុវត្ត)
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com